រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ២៥ អនក្រ.បក**

**ស្តីពីការដកខ្ទង់ចំណាយឥតគ្រោងទុក**

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស.រកម.១២៩៥.០៧ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៥ ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦ ការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៦ ។
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**សំរេច**

**មាត្រា ១** : អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដកថវិកាជារូបិយប័ណ្ណក្នុងខ្ទង់ចំណាយឥតគ្រោង ទុកចំនួន១.៤០២.៩២៨,០០$US (មួយលានបួនរយពីរពាន់ប្រាំបួនរយម្ភៃប្រាំបីដុល្លារអាមេរិកគត់) សំរាប់ដោះស្រាយ ។

- បន្ថែមចំណាយសាងសង់បន្ទាយសុវត្ថិភាពសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ ចំនួន ៦៨៣.០៩៨ $ ។

- បន្ថែមចំណាយសាងសង់បន្ទាយសវត្ថិភាពសម្តេចនាយករដ្ឋមន្ត្រីទី២ចំនួន ៧១៩.៨៣០ SUS ។

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ២៦ អនក្រ.បក**

**ស្តីពីការបង្កើត ស្រុក កំពង់សីលា**

**ចំណុះខេត្តកោះកុង**

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២នៃរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

**សំរេច**

**មាត្រា ១** : ត្រូវបានបង្កើតស្រុកកំពង់សីលា ដោយកាត់យកភូមិសាស្ត្រស្រុកស្រែអំបិល នៃខេត្តកោះកុងទៅតាមផែនទីរដ្ឋបាលភ្ជាប់ជាមួយអនុក្រឹត្យ ។